**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការត្រួតពិនិត្យ និងតាមដានសុខភាពអ្នកជាប់ឃុំឃាំង
# នៅក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩

យោងតាមសេចក្តីថ្លែងការរួមរបស់អង្គការលើកលែងទោសអន្តរជាតិ អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពី ប្រទេសកម្ពុជា៖ ភាពចាំបាច់ដើម្បីការពារអ្នកជាប់ឃុំពីជំងឺកូវីដ-១៩។

ក្រសួងសុខាភិបាលសូមជម្រាបជូនសាធារណជន អង្គការជាតិ និងអន្តរជាតិ រួមទាំងអង្គការខាងលើនេះថា រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការគោរពសិទ្ធិមនុស្ស និងការយកចិត្តទុកដាក់លើការផ្តល់សេវាសុខភាពជូនប្រជាជនទូទៅ ដោយមិនរើសអើងវណ្ណៈ ពូជសាសន៍ ព័ណ៌សម្បុរ ឬអ្នកជាប់ពន្ធនាគារនោះឡើយ ដើម្បីទទួលសេវាសុខភាពស្មើៗគ្នាដោយមិនមានការរើសអើងឡើយ ជាពិសេសជនងាយរងគ្រោះ ជនក្រីក្រ ជនពិការមនុស្សចាស់ជរា ស្ត្រី និងកុមារ ត្រូវបានទទួលការគាំទ្របន្ថែមទាំងផ្នែកហិរញ្ញវត្ថុ និងសង្គម ដើម្បីពួកគាត់អាចទទួលបានសេវាសុខាភិបាលប្រកបដោយសមភាព គុណភាព និងតម្លាភាព។

ទាក់ទងនឹងវិធានការណ៍ការពារការចម្លងវីរុសកូវីដ-១៩ ក្នុងចំណោមអ្នកជាប់ឃុំឃាំង កន្លងមកក្រសួងសុខាភិបាល បានសហការយ៉ាងជិតស្និទ្ធជាមួយអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ដើម្បីតាមដានមើលជាប្រចាំ នូវស្ថានភាពជំងឺផ្តាសាយធំ និងជំងឺកូវីដ-១៩ ដោយអគ្គនាយកដ្ឋានពន្ធនាគារបានយកចិត្តទុកដាក់បន្ថែម ក្នុងការតាមដានសុខភាពអ្នកជាប់ឃុំឃាំង និងរាយការណ៍មកក្រសួងសុខាភិបាល ក្នុងករណីមានការសង្ស័យលើបញ្ហាសុខភាពអ្វីមួយ ដែលកន្លងមកនេះ ក្រសួងបានធ្វើអន្តរាគមន៍ជួយពិនិត្យ និងព្យាបាលដល់អ្នកជាប់ឃុំឃាំងដែលមានជំងឺផ្តាសាយធំនៅតាមបណ្តាខេត្តមួយចំនួនរួចមកហើយ រហូតពួកគេបានជាសះស្បើយ។

ចាប់តាំងពីពេលមានការផ្ទុះ "ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា" នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០មក អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ បានតាមដានស្រាវជ្រាវរកករណីពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍នេះ ហើយមានបុគ្គលណាខ្លះ ដែលបានមកពាក់ព័ន្ធនឹងពន្ធនាគារ ព្រមទាំងបានតាមដានសុខភាពអ្នកជាប់ឃុំឃាំងកាន់តែហ្មត់ចត់ថែមទៀត។ របាយការណ៍របស់អគ្គនាយកដ្ឋានពន្ធនាគារបង្ហាញថា មិនមានអ្នកប៉ះពាល់នឹង "ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា" ណាម្នាក់ មានការប្រាស្រ័យទាក់ទងជាមួយអ្នកជាប់ឃុំឃាំងឡើយ ហើយចាប់ពីថ្ងៃទី០១ ដល់ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ មណ្ឌលអប់រំកែប្រែទី១ មិនមានករណីជំងឺផ្តាសាយធំដែលមានការសង្ស័យថាជាប់ពាក់ព័ន្ធទៅនឹង ការចម្លងវីរុសកូវីដ-១៩ ទាំងក្នុងចំណោមមន្ត្រី (ចំនួន ៣៥៤នាក់) និងអ្នកជាប់ឃុំឃាំង (ចំនួន ៧៦០៨នាក់) ឡើយ។ លើសពីនេះទៀត បន្ទាប់ពីបានទទួលព័ត៌មានតាម

រយៈបណ្តាញសារព័ត៌មាន អំពីការផ្ទុះឡើងជំងឺផ្តាសសាយធំនៅមណ្ឌលអប់រំកែប្រែទី១ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០២០ មក ក្រសួងសុខាភិបាល បានចាត់មន្ត្រីក្រុមឆ្លើយតបបន្ទាន់ចុះជាបន្ទាន់ទៅកាន់មណ្ឌលអប់រំកែប្រែទី ១ នៅយប់ថ្ងៃទី០៩ និងនៅព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ ដើម្បីពិនិត្យមើលស្ថានភាពសុខភាពអ្នកជាប់ឃុំឃាំងដោយផ្ទាល់ ហើយរបាយការណ៍របស់អគ្គនាយកដ្ឋានពន្ធនាគារ មណ្ឌលអប់រំកែប្រែទី១ ជាផ្លូវការ បានបង្ហាញថា មិនមានករណីជំងឺផ្តាសាយធំក្នុងចំណោមអ្នកជាប់ឃុំឃាំងនៅទីនោះឡើយ។

ក្រសួងសុខាភិបាល សូមបញ្ជាក់ថា ក្រសួង នៅតែបន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ និងអាជ្ញាធរថ្នាក់ក្រោមជាតិនៅតាមបណ្តារាជធានី-ខេត្តទាំងអស់ ដើម្បីតាមដានមើលជាប្រចាំនូវស្ថានភាពជំងឺផ្តាសាយធំ ដែលអាចសង្ស័យថាជាជំងឺកូវីដ-១៩ នៅតាមមណ្ឌលអប់រំកែប្រែទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា និងជំរុញឲ្យអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ បន្តយកចិត្តទុកដាក់អនុវត្តវិធានការណ៍របស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ក្នុងចំណោមអ្នកជាប់ឃុំឃាំងផងដែរ។

ក្រសួងសុខាភិបាលសូមអំពាវនាវដល់គ្រប់ស្ថានប័នពាក់ព័ន្ធ ចូលរួមអនុវត្តវិធានការណ៍របស់ក្រសួងសុខាភិបាល ក្នុងស្មារតីរក្សាសមភាព និងសាមគ្គីភាពគ្នា ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០


ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩